# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ០០៤៧/២៣ ក.ប/ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារ
## សុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត

## ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម ០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ/បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

# សម្រេច

**ប្រការ ១**.- បង្កើតក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត សរសេរអក្សរកាត់ថា "ស.ផ.ក" ។ ក្រុមការងារនេះ មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោក អ៊ុក សមវិទ្យា | នាយកបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២. លោក ព្រាប ច័ន្ទវិបុល | ប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក នៃក្រសួងសាធារណៈការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣. លោកវរសេនីយ៍ឯក លុយ ឈីន | អនុប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់នៃអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤. លោកវេជ្ជបណ្ឌិត នាង ភារិទ្ធ | អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ នៃក្រសួងសុខាភិបាល | អនុប្រធាន |
| ៥. លោកស្រី គឹម សេដ្ឋានី | នាយិកាទីចាត់ការកិច្ចការច្បាប់ និងសិទ្ធិមនុស្ស នៃគណៈកម្មការសុវត្ថិភាពចរាចរណ៍ផ្លូវគោករាជធានី | សមាជិក |
| ៦. លោកវរសេនីយ៍ត្រី ម៉ក់ ណារិទ្ធ | នាយរងការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក នៃការិយាល័យចរាចរណ៍ផ្លូវគោករាជធានី | សមាជិក |
| ៧. លោកស្រី បុប្ផា ផានី | អនុប្រធានអង្គភាពផ្តល់ប័ណ្ណបើកបរនិងសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៃមន្ទីរសាធារណៈការ និងដឹកជញ្ជូនរាជធានីភ្នំពេញ | សមាជិក |
| ៨. លោក កាំង ម៉ូនីកា | ប្រធានផ្នែកអភិវឌ្ឍន៍ធុរកិច្ច នៃសមាគមនិយោជករោងចក្រកាត់ដេរនៅកម្ពុជា | សមាជិក |
| ៩. លោក សោម អូន | ប្រធានសភាសម្ព័ន្ធសហជីពជាតិកម្ពុជា នៃសភាសម្ព័ន្ធសហជីពជាតិកម្ពុជា | សមាជិក |
| ១០. លោក គង់ អាទិត្យ | អនុ.សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា នៃសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា | សមាជិក |
| ១១. លោក គង់ រតនៈ | មន្ត្រីសម្របសម្រួលគម្រោងផ្នែកគាំទ្ររដ្ឋាភិបាល នៃអង្គការ HANDICAP International | សមាជិក |
| ១២. លោក ជាវ ប៊ុនរិទ្ធ | ប្រធានការិយាល័យគោលនយោបាយ នៃបេឡាជាតិរបបសន្តិសុខសង្គម | លេខាធិការ |

**ប្រការ ២.-** ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិតមានភារកិច្ច ៖

- កសាងផែនការសកម្មភាពសំដៅទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកដែលអាចកើតមានក្នុងពេលកម្មករនិយោជិតធ្វើដំណើរ
- សិក្សាស្រាវជ្រាវ ប្រមូលទិន្នន័យ វិភាគរកមូលហេតុចំបងៗ ដែលនាំឲ្យកើតមានគ្រោះថ្នាក់ចរាចរណ៍ ក្នុងការធ្វើដំណើររបស់កម្មករនិយោជិត
- ស្រង់ស្ថិតិមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត និងអ្នកបើកបរ តាមរោងចក្រ សហគ្រាសទូទាំងប្រទេស
- រៀបចំវិធានការផ្សព្វផ្សាយអប់រំ ណែនាំ ស្តីពីច្បាប់ និងសុវត្ថិភាពចរាចរណ៍ដល់អ្នកបើកបរ និងកម្មករនិយោជិត
- សហការជាមួយអាជ្ញាធរដែនដី សមត្ថកិច្ចពាក់ព័ន្ធ រួមបញ្ចូលទាំងសមត្ថកិច្ចចរាចរណ៍ផ្លូវទឹក ក្នុងការចុះត្រួតពិនិត្យមធ្យោបាដឹកជញ្ជូនកម្មករនិយោជិត តាមគោលដៅដើមទីមុនពេលចេញដំណើរ និងសម្របសម្រួលករណីកម្មករនិយោជិតជួបគ្រោះថ្នាក់ចរាចរណ៍
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**ប្រការ ៣.-** ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិតត្រូវប្រជុំយ៉ាងតិចមួយ (០១) លើក ក្នុងរយៈពេល ៣ ខែ។ ប្រធានអាចកោះអញ្ជើញប្រជុំវិសាមញ្ញបានតាមតម្រូវការការងារចាំបាច់ ។ ក្រុមការងារនេះ មានលេខាធិការដ្ឋាននៅបេឡាជាតិរបបសន្តិសុខសង្គម ។

**ប្រការ ៤.-** ការចំណាយលើសម្ភារៈ និងមធ្យោបាយក្នុងការបំពេញការងាររបស់ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត ជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម ។

**ប្រការ ៥.-** ក្រុមការងារអាចស្វែងរក និងប្រើប្រាស់ប្រភពជំនួយថវិកា សម្ភារៈ និងបច្ចេកទេស ពីដៃគូអភិវឌ្ឍន៍នានា ។

**ប្រការ ៦.-** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសម្រេចនេះចាត់ទុកជានិរាករណ៍។

**ប្រការ ៧.-** ប្រធាន អនុប្រធាន សមាជិក ដូចមានចែងក្នុងប្រការ១ និងនាយកបេឡាជាតិរបបសន្តិសុខសង្គម ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមករា ឆ្នាំ ២០១៧

**រដ្ឋមន្ត្រី**

**ឧក សុត**

<u>កន្លែងទទួល៖</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ក្រុមប្រឹក្សាបច្ចេកទេស នៃប.ស.ស
- ក្រុមប្រឹក្សាភិបាល នៃប.ស.ស
- សាមីអង្គភាព "ដើម្បីជូនជ្រាប"
- ដូចប្រការ៧ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ